# ពិធីចូលឆ្នាំប្រពៃណីជាតិខ្មែរ

## ១.ការកំណត់ថ្ងៃចូលឆ្នាំថ្មីប្រពៃណីខ្មែរ

ការកំណត់ថ្ងៃខែចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរយើងតាំងពីយូលង់ណាស់មកហើយនោះគឺកំណត់យកតាមចន្ទគតិគឺកំណត់យកខែមិគសិរជាដើមឆ្នាំ។តាមចន្ទគតិគេកំណត់បែកចែកជា៣រដូវកាលធំៗនោះគឺៈ

១.ហេមន្តរដូវ ចាប់គិតពីថ្ងៃ១រោចខែកត្តិកដល់ថ្ងៃពេញបូរណ៌មីខែផល្គុន។ ហេមន្តរដូវនេះ ជារដូវត្រជាក់ត្រូវចាត់ទុកជាដើមឆ្នាំលោកប្រៀបថាជាពេលវេលាពេលព្រឹក។

២. គិម្ហរដូវ ចាប់គិតពីថ្ងៃ១រោចខែផល្គុនដល់ថ្ងៃពេញបូរណ៌មីខែអាសាឍ។ គិម្ហរដូវជារដូវក្តៅខ្លាំងចាត់ទុកជាកណ្តាលឆ្នាំលោកប្រៀបថាជាពេលវេលាពេលថ្ងៃត្រង់។

៣. វស្សានរដូវចាប់គិតពីថ្ងៃ១រោចខែអាសាឍដល់ថ្ងៃពេញបូរណ៌មីខែកត្តិក។ វស្សានរដូវជារដូវមេឃមីស្រទុំងងឹតនិងមានភ្លៀងផ្គរលោកចាត់ទុកថាជាចុងឆ្នាំប្រៀបថាជាពេលវេលាពេលល្ងាច។[១]

បុរាណាចារ្យកំណត់យកខែមិគសិរជាខែទីមួយនៅក្នុងចន្ទគតិ ខែបុស្សជាខែទី២ រៀងទៅដល់ខែកត្តិកជាខែទី១២។

ចន្ទគតិ ដំណើរនៃព្រះចន្ទនោះកំណត់តាមក្បួនហោរមួយជុំពិតពម្តងគឺ ក្នុងរវាង២៩ថ្ងៃជាងកន្លះរាប់ជាមួយខែ និង១២ខែរាប់ជាមួយឆ្នាំ តែបើមានលើកអធិមាស គឺ១៣ខែជាមួយឆ្នាំ។ រដូវតាមចន្ទគតិនោះមិនទៀងត្រង់តាមធម្មតារហូតទៅ។ បុរាណាចារ្យគិតថា ប្រសិនបើយើងកំណត់យកប្រើតែចន្ទគតិ១យ៉ាង ច្រើនពាន់ឆ្នាំទៅខាងមុខទៀតនឹងត្រលប់ប្រែប្រួលរដូវ ដូចជារដូវរងាក្លាយជារដូវក្តៅ ហើយរដូវក្តៅក៏ក្លាយជារដូវមានភ្លៀងធ្លាក់ទៅវិញ។[២]

លុះក្រោយមកប្រមាណពីពេលដែលផ្តើមប្រើចុល្លសករាជមកទើបប្រើសុរិយគតិជាសំខាន់វិញហើយកំណត់ចូលឆ្នាំនៅក្នុងខែចេត្រ ដែលជារដូវក្តៅដរាបដល់សព្វថ្ងៃនេះ។ សុរិយគតិមាន១២ខែដូចគ្នានិងចន្ទគតិដែរ តែការហៅខុសគ្នា ដូចជាៈ ១.មេសាយន ២.ព្រឹសភាគម ៣. មិថុនាយន...រហូតដល់ ទី១២. មីនាគម។ ចំណាំខែដែល

---

[១] ក្រុមជំនុំទំនៀមទម្លាប់ ព្រះរាជពិធីទសមាសភាគទី១ បោះពុម្ពលើកទី៣ឆ្នាំ១៩៦៩ទំព័រទី១

[២] ក្រុមជំនុំទំនៀមទម្លាប់ ព្រះរាជពិធីទសមាសភាគទី១ បោះពុម្ពលើកទី៣ឆ្នាំ១៩៦៩ទំព័រទី២

មានយននៅខាងចុងខែនោះមាន៣០ថ្ងៃ រីឯខែណាដែលមានគមនៅខាងចុងគឺមាន៣១ថ្ងៃ។ ចំពោះខែដែលគ្មានយន និងគម គឺជាខែដែលមានតែ២៨ថ្ងៃបើឆ្នាំណាត្រូវបន្ថែមថ្ងៃក៏ឡើងជា២៩ថ្ងៃ។[៣]

សុរិយគតិមាន៤រដូវគឺៈ

១. សិសិរ  ចាប់គិតនៅក្នុងខែមីនា ដល់មិថុនា

២. និទាឃ  ចាប់គិតនៅក្នុងខែ មិថុនាដល់ខែកន្យា

៣.វស្សាន  ចាប់គិតនៅក្នុងខែកន្យា ដល់ខែធនុ

៤.សារទ  ចាប់គិតនៅក្នុងខែធនុ ដល់មីនា

ប្រទេសកម្ពុជាយើងក្នុងសម័យនោះប្រើសុរិយគតិអែបនិងចន្ទគតិហើយកំណត់ខែទី៥គឺខែចេត្រដើមឆ្នាំកំណត់ព្រះអាទិត្យចូលកាន់មេសរាសី ដែលជាសាមញ្ញសង្ក្រាន្តគឺព្រះអាទិត្យដើរត្រង់ពីលើក្បាលជាសង្ក្រាន្តវិញមិនយកតាម អាយន្តសង្ក្រាន្តដូចមុន។ដូច្នេះថ្ងៃចូលឆ្នាំរមែងត្រូវលើថ្ងៃទី១៣ខែមេសៈជាដរាបរាល់ៗឆ្នាំ។ រីឯការកំណត់តាមអាយន្តសង្ក្រាន្ត(ចន្ទគតិ) នៅថ្ងៃចូលឆ្នាំមិនបានទៀងនឹងជាថ្ងៃណាមួយ។ ចួនកាលឆ្នាំនេះចូលក្នុងថ្ងៃនេះហើយឆ្នាំក្រោយចូលនៅក្នុងថ្ងៃឯណោះទៅវិញ មានខ្នើតមានរនោចមិនត្រង់គ្នា គ្រាន់តែមានកំណត់ទុកថាសង្ក្រាន្តមានក្នុងរវាង១ខែគឺមិនមុនថ្ងៃទី៤កើតខែចេត្រនិងមិនហួសថ្ងៃទី៤កើតខែពិសាខ។ដូច្នេះឃើញថាសង្ក្រាន្តឆ្នាំខ្លះធ្លាក់ទៅដល់ខែពិសាខក៏មានដែរ។[៤]

## ២.រឿងព្រេងនិទានទាក់ទងនិងប្រវត្តិចូលឆ្នាំប្រពៃណីខ្មែរ

សង្ក្រាន្តគឺជាទំនៀមដាច់ឆ្នាំចាស់ចូលឆ្នាំថ្មីដែលមានតាំងពីបុរាណកាលមកហើយ តែមកក្នុងសម័យមួយមានអ្នកប្រាជ្ញម្នាក់មិនប្រាកដឈ្មោះបានរៀបរៀងជារឿងនិទានហៅថា«សង្ក្រាន្តសូត្រ»ប្រកបឡើងផង។ សូមនិទានដោយសង្ខេបដូចតទៅៈ

ក្នុងកាលនោះមាន ភទ្ទកប្បនេះមានបុរសម្នាក់ឈ្មោះធម្មបាល ជាបុត្ររបស់សេដ្ឋី ជាអ្នកមានចំណេះវិជ្ជាដ៏វិសេសរៀនចេះចប់ត្រៃវេទតាំងពីអាយុ៧ឆ្នាំ។ សេដ្ឋីជាបិតាបានសាងប្រាសាទឱ្យនៅទៀបដើមជ្រៃធំមួយនៅក្បែរឆ្នេរទន្លេដែលជាទីលំនៅរបស់បក្សីទាំងឡាយ។ ធម្មបាលកុមារបានចេះភាសាបក្សីទាំងពួងផង  ហើយបានជាអាចារ្យសម្តែងមង្គលផ្សេងៗដល់មនុស្សទាំងពួង។ កាលគ្រានោះមនុស្សលោករាប់អានព្រះមហាព្រហ្មនិងកបិលមហាព្រហ្ម

---

[៣] ក្រុមជំនុំទំនៀមទម្លាប់ ព្រះរាជពិធីទសមាសភាគទី១  បោះពុម្ពលើកទី៣ឆ្នាំ១៩៦៩ទំព័រទី៥

[៤] ក្រុមជំនុំទំនៀមទម្លាប់ ព្រះរាជពិធីទសមាសភាគទី១  បោះពុម្ពលើកទី៣ឆ្នាំ១៩៦៩ទំព័រទី៦

មួយអង្គទៀតថាជាអ្នកសម្ដែងមង្គលដល់មនុស្សទាំងពួង។កាលកបិលមហាព្រហ្មជ្រាបព័ត៌មាននេះក៏ចុះមកសួរបញ្ហានឹងធម្មបាលកុមារ៣ខ សន្យាទុកថា បើសិនជាដោះបាននឹងកាត់ក្បាលបូជាធម្មបាលកុមារ បើដោះមិនបាននឹងកាត់ក្បាលធម្មបាលកុមារបូជាវិញ។ធម្មបាលកុមារសុំឱ្យបង្អង់៧ថ្ងៃសិនដើម្បីគិតប្រាស្នា។ លុះវេលាកន្លងទៅ៦ថ្ងៃហើយក៏គិតប្រស្នានោះមិនឃើញ ធម្មបាលកុមារដឹងខ្លួនថា ព្រឹកនេះនឹងត្រូវស្លាប់ដោយអាជ្ញាកបិលមហាព្រហ្មជាប្រាកដហើយ ដូច្នេះគួរអញរត់ទៅពាក់ពួនលាក់ខ្លួនឱ្យស្លាប់បង់ដោយខ្លួនឯងប្រសើរជាង ទើបចុះពីប្រាសាទទៅដេកពួកនៅក្រោមដើមត្នោតមួយគូ។ ដើមត្នោតនោះជាជម្រករបស់សត្វឥន្ទ្រីយញីឈ្មោលធ្វើសំបុកអាស្រ័យនៅ។

វេលាយប់មកដល់ឥន្ទ្រីញីសួរទីឥន្ទ្រីយឈ្មោលថា តើស្អែកនេះយើងបានអាហារពីណាស៊ី? ឥន្ទ្រីយឈ្មោលក៏ឆ្លើយថា យើងនឹងបានស៊ីសាច់ធម្មបាលកុមារដែលត្រូវកបិលមហាព្រហ្មសម្លាប់ព្រោះដោះប្រស្នាមិនរួច។ ឥន្ទ្រីយញីសួរថាតើប្រស្នានោះដូចម្ដេច? ឥន្ទ្រីយឈ្មោលឆ្លើយថា វេលាពេលព្រឹកសេរីស្កិតនៅទីណា? ត្រូវឆ្លើយថានៅត្រង់មុខ ហេតុនេះមនុស្សទាំងឡាយត្រូវយកទឹកមកលុបមុខនៅពេលពួកគេក្រោកពីដំណេក។ ខ១មួយទៀតថា ថ្ងៃត្រង់សេរីស្កិតនៅត្រង់ណា?ត្រូវឆ្លើយថានៅទ្រូងហេតុនេះមនុស្សទាំងឡាយត្រូវយកទឹកមកលាងទ្រូង។ខ១មួយទៀតថាវេលាល្ងាចសេរីស្កិតនៅត្រង់ណា?ត្រូវឆ្លើយថានៅជើង ហេតុនេះមនុស្សទាំងឡាយទើបយកទឹកលាងជើង។

ធម្មបាលកុមារឮដូច្នេះក៏ត្រលប់ទៅប្រាសាទវិញ។ លុះព្រឹកឡើងកបិលមហាព្រហ្មក៏មកដល់ហើយសួរប្រស្នា ធម្មបាលកុមារក៏ឆ្លើយដោះស្រាយតាមដែលបានឮមក។ កបិលមហាព្រហ្មក៏ហៅបុត្រីទាំង៧នាក់ជាបាទបរិចារិកាព្រះឥន្ទ្រមកប្រាប់ថា ឥឡូវបិតាត្រូវកាត់ក្បាលបូជាធម្មបាលកុមារ តែបើដាក់ក្បាលលើផែនដីក៏នឹងកើតជាភ្លើងឆេះទាំងលោកធាតុ បើបោះទៅលើអាកាសភ្លៀងក៏នឹងរាំង បើចោលទៅក្នុងសមុទ្រទឹកក៏រីងស្ងួតហួតអស់ទៅដូច្នេះសុំឱ្យកូនទាំង៧នាក់យកពានមកទទួលក្បាល។ ថារួចហើយកបិលមហាព្រហ្មក៏កាត់ក្បាលហុចទៅឱ្យនាងទុង្សាជាកូនច្បង។ នាងទុង្សាបានយកពានទៅទ្រក្បាលបិតាហើយហែប្រទក្សិណភ្នំព្រះសុមេរុ៦០នាទីហើយក៏អញ្ជើញប្រតិស្ឋានទុកក្នុងមណ្ឌបនៅក្នុងគុហាគន្ធមាលីភ្នំកៃលាស បូជាដោយគ្រឿងទិព្វផ្សេងៗ។

លុះដល់គម្រប់មួយឆ្នាំជាសង្ក្រាន្តនាងទេពធីតាទាំង៧ក៏ផ្លាស់វេនគ្នាមកអញ្ជើញក្បាលកបិលមហាព្រហ្មចេញមកហែប្រទក្សិណជុំវិញភ្នំសុមេរុរាល់ៗឆ្នាំហើយត្រលប់ទៅទេវលោកវិញ។[៥]

នៅក្នុងឱកាសសង្ក្រាន្តចូលឆ្នាំតាមទំនៀមហោរកំណត់ទុកគឺមាន៣ថ្ងៃ នៅថ្ងៃដំបូងហៅថាថ្ងៃមហាសង្ក្រាន្តថ្ងៃទី២ហៅថា វ័នបត ថ្ងៃទី៣ហៅថា ថ្ងៃឡើងស័ក។ នេះជាកិច្ចពិធីចូលឆ្នាំដែលគេប្រារព្ធធ្វើនៅក្នុងព្រះរាជវាំង។

[៥] ក្រុមជំនុំទំនៀមទម្លាប់ ព្រះរាជពិធីទសមាសភាគទី១ បោះពុម្ពលើកទី៣ឆ្នាំ១៩៦៩ទំព័រទី១១

## ៣.គ្រឿងរណ្តាប់និងកិច្ចពិធីចូលឆ្នាំសម្រាប់ប្រជាជនខ្មែរបច្ចុប្បន្ន

សម្រាប់ប្រជាជនខ្មែរទូទៅឱ្យតែដល់វេលាចូលឆ្នាំគឺតែងតែរៀបចំសម្អាតផ្ទះសម្បែង រៀបចំគ្រឿងរណ្តាប់ផ្សេងៗដើម្បីទទួលទេវតាជាពិសេស គឺត្រៀមសម្លៀកបំពាក់ថ្មីៗដើម្បីស្លៀកទទួលទេវតា និងត្រៀមទទួលពរជ័យពីទេវតាឆ្នាំថ្មីដែលបានយាងមកតាំងពីថ្ងៃទី១រហូតដល់ថ្ងៃបញ្ចប់។

**ក.គ្រឿងរណ្តាប់ទទួលទេវតារួមមានៈ**

.រៀបចំតុដែលមានកម្រាលស្អាតសមរម្យនិងមានគ្រឿងតុបតែងលម្អលើតុនោះផង

.មានបាសីស្រស់ឬបាយសីធ្វើពីក្រដាសបិតទិបមាស ៣ថ្នាក់និង៥ថ្នាក់និងកូនដើមចេកមួយដើមឬមួយគូដាក់លើតុ។

.រៀបចំផ្លែឈើចាប់ពី៥មុខឡើងទៅចំនួន២ថាសអាចលើសពីនេះក៏បាន

.មានផ្កាធ្មីដាក់ក្នុងថូមួយគូ

.ដាក់ទឹកមួយផ្តិលធំឬក៏ដាក់ទឹកចំនួន២កែវនៅផ្នែកកណ្តាល

.មានកំប៉ុងជើងធូបមួយដើម្បីដោតជើងធូបនិងទានមួយគូ

.ដាក់ទឹកអប់ ព្រេងម្សៅ ក្រែមនិងកញ្ចក់ ក្រាសសិតសក់នៅលើជើងពានតូចមួយ

.ដាក់អង្ករ ពោត សណ្តែក ស្រូវ ល្ង អំបិល នៅលើជើងពានតូចមួយ

**ខ.ការរៀបចំម្ហូបអាហារៈ**

ប្រជាជនខ្មែរទូទៅចូលចិត្តនិយមធ្វើម្ហូបអាហារណាដែលអាចទុកបានយូថ្ងៃសម្រាប់ពិធីចូលឆ្នាំប្រពៃណីខ្មែរ មានដូចជា ៖ សម្លរ ការី សម្លរខជើងជ្រូកនិងសម្លរផ្សេងៗដើម្បើទុកបានយូថ្ងៃ។

## ៤.ការចូលរួមសប្បាយរីករាយក្នុងឱកាសចូលឆ្នាំប្រពៃណីខ្មែរ

នេះគឺជាឱកាសមហាគ្រួសារខ្មែរដែលបានជួបជុំគ្នាពីព្រោះរយៈពេល៣ថ្ងៃត្រូវបានឈប់សម្រាក់ពីការហារទាំងស្ថាបន្ទជាតិនិងស្ថាបន្ទឯកជន។ ប្រជាជនមួយភាគធំត្រូវត្រលប់ទៅស្រុកកំណើតដើម្បីជួបជុំឪពុកម្តាយ បងប្អូន។ អ្នកខ្លះទៀតទៅធ្វើបុណ្យទាននៅតាមទីវត្តអារាមផ្សេងៗនិង អ្នកខ្លះដើរលេងកំសាន្តនៅតាមរមណីដ្ឋានប្រវត្តិសាស្ត្រឬក៏រមណីយដ្ឋានកំសាន្តនានានៅតាមតំបន់នានា។

តែអ្វីដែលមិនអាចបំភ្លេចបានគឺការចូលរួមលេងល្បែងប្រជាប្រិយរបស់ខ្មែរ ដែលដូនតាខ្មែរបានបន្សល់ទុកឱ្យ។ល្បែងទាំងអស់នោះរួមមាន៖ លេងឈូង  បោះអង្គុញ លាក់កន្សែង ទាញព្រ័ត ស្តេចចង់ ចាប់កូនខ្លែង  ដណ្តើមស្លឹកឈើ  ផ្កាចំប៉ាចំប៉ី  រុញអង្រែ ...និងរាំកំសាន្តតាមចង្វាក់ប្រពៃណីខ្មែរជាតិយើង។

នាងខ្ញុំសុំអភ័យទោសទុកជាមុននូវអត្ថបទស្រាវជ្រាវមួយនេះបើមានការកង្វះខាតណាមួយ។

.